# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេមបូឌា) ឯ.ក
# និង
# ជាមួយសហជីពនិងតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុន

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១០ និង ០០នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ន នៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងគ្មានការបញ្ជាទិញ ដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្ម ដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៧ នាក់ (ស្រី ១១នាក់)ក្នុង ចំណោមកម្មករនិយោជិតសរុបចំនួន ១៥០១នាក់ (ស្រី ៩៨៦នាក់) រយៈពេលព្យួរចំនួន ៣០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ហើយនៅក្នុងអំឡុងពេលព្យួរការងារ នេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៣០ ដុល្លារអាមេរិចក្នុងមួយខែ បើកមុនថ្ងៃព្យួរ  សម្រាប់កម្មករនិយោជិតម្នាក់ៗ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១០: ៣០ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសង់ខាងមានភាពស្និតស្នាល និងយោគយល់ និងសហការគ្នាយ៉ាងរលូន។

ថ្ងៃព្រហស្បតិ៍  ១៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ស្ពឺ, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេមបូឌា) ឯ.ក
SHUI YAT A (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

Huang Kaifa

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

| | | | | | |
|---|---|---|---|---|---|
| ញ៉េប សារ៉េន | ព្រំ សារ៉ាន់ | ឆុំ កែវសុវណ្ណា | ចាន់ ទូចស្រីនិច | យុត សុខេម | ពៅ អេន |
| ជា សោភា | អឿន ចាន់ថា | អុំ សូនី | ទេពហាន | ញឹម វណ្ណា | អួន សុភាក់ |
| ភ្លេក សុភ័ណ្ឌ | ហេង សុខនី | ផន អ៊ុនតាក់ | អ៊ឹម សុខកេម្មី | | |